# ទំនុកដំកើង ១២៤

អ្នកនិពន្ធ រ៉ុប្ លេភិឡារ

នៅក្នុងទំនុកដំកើងនេះស្ដេចដាវីឌបង្ហាញយើងថា នគររបស់ទ្រង់គឺស្ថិតក្នុងស្ថានភាពអស្ថេរភាពនិងគ្រោះថ្នាក់ ជាពិសេសដោយសារតែពួកភីលេស្ទីន។ ២សាំយ៉ូអែល ៥.១២...បង្ហាញថាការគំរៀមកំហែងមានលក្ខណៈធ្ងន់ធ្ងរណាស់ ហើយថាស្ដេចដាវីឌមិនបានមានទំនុកចិត្តខ្លាំងនៅក្នុងកំលាំងរបស់ខ្លួនឯងដើម្បីឲ្យរួចជីវិតនោះទេ។ ការឆ្មក់វាយលុកគឺមិនគ្រាន់ដើម្បីចាប់យកទឹកដីប៉ុណ្ណោះទេ តែគោលដៅនៃការឆ្មក់វាយលុកគឺដើម្បីបំផ្លាញស្ដេចដាវីឌ។

**ខ. ១, ២** រចនាសម្ព័ន្ធនៃខ១-២គឺមានមនុស្សម្នាក់ដែលធ្វើការប្រកាស ហើយបន្ទាប់មកអញ្ជើញអ៊ីស្រាអែលឲ្យចូលរួមនិយាយការប្រកាសឡើងវិញ។ នៅទីនេះការប្រកាសគឺ «បើមិនមែនជាព្រះយេហូវ៉ាដែលកាន់ខាងពួកយើង»។ មានទំនុកដំកើងផ្សេងៗទៀតដែលចាប់ផ្ដើមដោយរចនាសម្ព័ន្ធនេះ ដូចជា ១១៨.១-២ និង ១២៩.១-២។ ទំនុកដំកើង១២៤.១-២កំពុងពិពណ៌នាអំពីសង្គ្រាម ហើយថ្លែងថាអ្នកណាដែលឈ្នះការប្រយុទ្ធមិនពឹងផ្អែកលើអ្នកដែលខ្លាំងជាងនោះទេ ប៉ុន្តែជាអ្នកដែលព្រះនៅកាន់ខាងអ្នកនោះវិញ។ ដោយព្រោះព្រះនៅកាន់ខាងប្រជារាស្ត្ររបស់ទ្រង់ នោះពួកគេបានឈ្នះបើទោះជាពួកគេខ្សោយជាងពួកខ្មាំងសត្រូវខ្លាំងយ៉ាងណាក៏ដោយ។

**ខ. ៣** ខ៣-៧ក្នុងទំនុកដំកើងនេះ មានរូបភាពបីឬបួនដើម្បីពណ៌នាអំពីមហន្តរាយដែលស្ទើរបានបំផ្លាញពួកគេទៅហើយ។ រូបភាពទីមួយនៅក្នុងខ. ៣ខ គឺជាសត្វចំឡែកដែលអាចស៊ីរំពារបស់វាតែមួយម៉ាត់ ឬសាស្ត្រាចារ្យព្រះគម្ពីរខ្លះជឿថាខគម្ពីរនេះកំពុងសំដៅលើការរញ្ជួយដីមួយ (សូមមើល ជនគណនា ១៦.៣០-៣៣)។

**ខ. ៤, ៥** ពាក្យប្រៀបរូបភាពទីពីរគឺអំពីទឹកជំនន់និងទឹកជ្រោះវល់ច្របល់។ ប្រសិនបើព្រះជាម្ចាស់មិនបានការពារអ៊ីស្រាអែល នោះពួកគេនឹងត្រូវបានបរាជ័យដូចជាទឹកជ្រោះហូរគ្របលើពួកគេទៅហើយ (៤ខ)ប៉ុន្តែព្រះបានបំផ្លាញពួកភីលេស្ទីន «ដូចជាទឹកធ្លាយទំនប់» (២សាំយ៉ូអែល ៥.២០)។ សំរាប់ឧទាហរណ៍មួយទៀតអំពីរូបភាពមួយនៃពលទ័ពដែលវាយដណ្ដើមទាំងអស់ សូមមើលអេសាយ ៨.៧-៨។

**ខ.៦** រូបភាពនេះខុសគ្នាបន្តិចនឹងរូបភាពដែលនៅក្នុងខ៣។ ខ.៣ ពណ៌នាអំពីការដែលសត្វសាហាវបានស៊ីរំពារបស់វាយ៉ាងលឿនៗ។ ប៉ុន្តែក្នុងខ.៦ នេះរំពាររឹតតែមានការឈឺចាប់ខ្លាំងជាងដោយសារត្រូវបានសត្វសាហាវស៊ីយ៉ាងយឺតៗវិញ។ ដូចជាការហែកនិងកិនរំពារ។ ការឆ្លើយតបដ៏ត្រឹមត្រូវទៅចំពោះព្រះដែលសង្គ្រោះយើងគឺត្រូវតែច្រៀងសរសើរតម្កើងទ្រង់។

**ខ.៧** ពាក្យប្រៀបចុងក្រោយគឺអំពីអន្ទាក់របស់នាយព្រាន។ រូបភាពអំពីនាយព្រានកំពុងដាក់អន្ទាក់សត្វស្លាបដោយសំណាញ់និងអន្ទាក់គឺជាពាក្យប្រៀបមួយដែលគេប្រើយ៉ាងសាមញ្ញ (សូមមើលយ៉ូស្វេ ២៣.១៣, ទំនុកដំកើង ៦៩.២២, អេសាយ ៨.១៤)។ មានបច្ចេកទេសខុសៗគ្នាមួយចំនួនត្រូវបានប្រើសំរាប់ការអន្ទាក់សត្វស្លាប។ ទោះបើពួកអ្នកប្រម៉ាញ់អាចប្រើចំពាម ចោលដំបងឬបាញ់ព្រួញ ក៏ក្នុងករណីភាគច្រើននៅក្នុងព្រះគម្ពីរហើយនិងក្នុងសិល្បៈបុរាណពណ៌នាអំពីហ្វូងសត្វស្លាបធំកំពុងជាប់នៅក្នុងសំណាញ់ឬទ្រុងដែរ។ ពាក្យប្រៀបទាំងនេះបង្ហាញអំពីរូបភាពនៃការបំផ្លាញដែលដូចជាមិនទំនងនឹងអាចគេចរួចបាននោះទេ ប៉ុន្តែព្រះជាម្ចាស់បានសង្គ្រោះពួកគេ។ ពាក្យប្រៀបទាំងនេះប្រកាសថាពួកគេពិតជានឹងបានបរាជ័យប្រសិនបើព្រះមិនបានកាន់ខាងពួកគេ ដែលនេះសង្កត់ធ្ងន់ថា ជ័យជំនះរបស់ពួកគេគឺបានមកដោយសារតែព្រះជាម្ចាស់ប៉ុណ្ណោះ គឺមិនមែនដោយសារកំលាំងផ្ទាល់របស់ពួកគេនោះឡើយ។

**ខ. ៨** ស្ដេចដាវីឌសំលឹងទៅឯព្រះអាទិករ មិនមែនសំលឹងទៅឯគ្រឿងសព្វាវុធរបស់មនុស្សជាតិដើម្បីសង្គ្រោះពួកគេនោះទេ។ សេចក្ដីពិតខាងប្រវត្តិសាស្ត្រគឺថា ព្រះពិតជាបានសង្គ្រោះពួកគេមែន ដូច្នេះនេះបង្ហាញថាទ្រង់មានអំណាចលើសជាងកំលាំងទ័ពនិងគ្រឿងសព្វាវុធខ្លាំងពូកែដែលវាយប្រឆាំងនឹងប្រជារាស្ត្ររបស់ទ្រង់។ ស្ដេចដាវីឌបានរស់នៅក្នុងសេចក្ដីជំនឿលើព្រះដែលទ្រង់មើលមិនឃើញ ហើយដឹងថាព្រះមួយអង្គនេះអាចនឹងបំបាក់ពួកខ្មាំងសត្រូវរបស់ទ្រង់ដែលទ្រង់អាចមើលឃើញ (ប្រៀបធៀបៈ ទំនុកដំកើង

២០.៧)។ ក្រោយមកទៀត ប្រជារាស្ត្ររបស់ព្រះត្រូវបានបន្ទោស ពីព្រោះគេទុកចិត្តលើសម្ព័ន្ធមិត្តជាមួយអេស៊ីព្ទជាជាងទុកចិត្តលើព្រះ (អេសាយ ៣១.១)។

**ការអនុវត្ត**

ទំនុកដំកើងនេះបង្ហាញថាស្តេចដាវីឌគឺជាបុរសនៃសេចក្តីជំនឿម្នាក់។ ទ្រង់បានសំលឹងទៅឯព្រះដើម្បីឲ្យព្រះសង្គ្រោះទ្រង់ ហើយដាវីឌបានសរសើរតម្កើងព្រះនៅពេលទ្រង់បានសង្គ្រោះ។ ដាវីឌបានយល់ថាវាគឺជាសេចក្តីពិតដែលថាព្រះបានកំពុងធ្វើសកម្មភាពសំរាប់ប្រជារាស្ត្ររបស់ទ្រង់ ហើយបានជួយពួកគេឲ្យរួចជីវិត។ (ហើយ នៅពេលដែលព្រះប្រឆាំងនឹងមនុស្ស នោះគេនឹងត្រូវបានវិនាស)។ ព្រះគម្ពីរសញ្ញាថ្មីបង្រៀនថា ព្រះនៅកាន់ខាងពួកគ្រីស្ទបរិស័ទ (រ៉ូម ៨.៣១) ហើយដោយសារតែព្រះនៅកាន់ខាងពួកយើង នោះការវាយប្រហាររបស់អស់អ្នកដែលប្រឆាំងនឹងយើងនឹងមិនឈ្នះយើងឡើយ។ យើងនឹងមានទុក្ខលំបាកនិងការបៀតបៀន ប៉ុន្តែមិនថាអារក្ស ឬសេចក្តីស្លាប់ឬអំណាច ក៏មិនអាចពង្រាត់យើងចេញពីសេចក្តីស្រលាញ់នៅក្នុងព្រះគ្រីស្ទយេស៊ូវបានឡើយ (រ៉ូម ៨.២៨-៣៩)។ សេចក្តីពិតនេះលើកទឹកចិត្តយើងឲ្យរក្សាសេចក្តីជំនឿនៅក្នុងព្រះគ្រីស្ទ ពីព្រោះទ្រង់គួរឲ្យទុកចិត្តបានទាំងស្រុង។

## Bibliography


Carson, D.A., R. T. France, J. A. Motyer & G. J. Wenham, Ed. (1994), *New Bible commentary: 21st century edition*, (4th ed.) Leicester, England; Downers Grove, IL: Inter-Varsity Press.

Henry, M. (1994), *Matthew Henry's commentary on the whole Bible: Complete and unabridged in one volume*, Peabody: Hendrickson.

Kidner, D. (1975). *Vol. 16*: *Psalms 73–150: An Introduction and Commentary*. Tyndale Old Testament Commentaries. Nottingham, England: Inter-Varsity Press.

Matthews, V. H., M. W. Chavalas & J.H. Walton (2000), *The IVP Bible background commentary: Old Testament*, Downers Grove, IL: InterVarsity Press.

Wilcock, Michael. (2001), *The Message of Psalms 73-150.* The Bible Speaks Today Commentaries. Leicester, England: Inter-Varsity Press.